បណ្ណព័ត៌មានអំពីជំងឺឆ្លង

# ជំងឺ Rotavirus

*ក្នុងពិភពលោក **rotavirus** គឺជាមូលហេតុទូទៅបំផុតនៃជំងឺរលាកក្រពះនិងពោះវៀនក្នុងចំណោមកុមារក្មេងខ្ចី ដោយយាយីកុមារសឹងតែទាំងអស់ដែលមានអាយុតិចជាងប្រាំឆ្នាំ។ ឥឡូវនេះមានថ្នាំបង្ការរោគសំរាប់កូនក្មេង។*

## តើជំងឺ rotavirus គឺជាអ្វី?

ក្នុងពិភពលោក rotavirus គឺជាមូលហេតុទូទៅបំផុតនៃជំងឺរលាកក្រពះនិងពោះវៀនដ៏ធ្ងន់ធ្ងរក្នុងចំណោមកុមារក្មេងខ្ចី។ កុមារសឹងតែទាំងអស់បានកើតជំងឺនេះនៅនឹងពេលដែលកុមារទាំងនោះឈានដល់អាយុប្រាំឆ្នាំ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ rotavirus ទទួលខុសត្រូវចំពោះការបាត់បង់ជីវិតមនុស្សចំនួនប្រហែលប្រាំសែននាក់ក្នុងមួយឆ្នាំៗ។ នៅក្នុងប្រទេសអភិវឌ្ឍន៍ដូចជាប្រទេសអូស្ត្រាលីជាដើម ការបាត់បង់ជីវិតដោយ rotavirus កំរកើតមានណាស់ ប៉ុន្តែការចូលព្យាបាលក្នុងមន្ទីរពេទ្យដោយសារជំងឺនេះគឺជាហេតុការណ៍ទូទៅ ជាពិសេសចំពោះកុមារមានអាយុតិចជាង 2 ឆ្នាំ។

## តើជំងឺនេះមានរោគសញ្ញាអ្វីខ្លះ?

រោគសញ្ញាទាំងឡាយមានរួមទាំង៖

- រាកមានលាមករាវដូចទឹក
- ក្អួត
- គ្រុនក្តៅ

នៅក្នុងករណីខ្លះ ការបាត់បង់ជាតិទឹកដ៏ខ្លាំង និងការបាត់បង់ជីវិត(ដោយកំរ)អាចកើតមានឡើង។ កូនក្មេងខ្លះ (ជាពិសេសអាយុតិចជាង 3 ខែ) ដែលកើតជំងឺ rotavirus ប្រហែលជាមិនបង្ហាញរោគសញ្ញាណាមួយឡើយ។ ជាធម្មតា រោគសញ្ញាទាំងឡាយលេចចេញឡើងនៅចន្លោះពេលពី 1 ទៅ 3 ថ្ងៃ (ជាទូទៅគឺ 2 ថ្ងៃ) ក្រោយពីបានឆ្លងវីរុសនេះ។

ភាគច្រើននៃអ្នកមានសុខភាពល្អដែលបានឆ្លងវីរុសនេះ ជួបប្រទះនឹងការធ្លាក់ខ្លួនឈឺរយៈពេល 4 ទៅ 6 ថ្ងៃ ហើយជាសះស្បើយពេញលេញមកវិញ។ ជំងឺ rotavirus ច្រើនកើតមាននៅរដូវរងា។

## តើជំងឺនេះឆ្លងតាមរបៀបណា?

Rotavirus គឺជាជំងឺឆ្លងយ៉ាងខ្លាំង ហើយឆ្លងដោយសារកម្ទួតឬលាមករបស់អ្នកកើតជំងឺ តាមរយៈ៖

- ការប៉ះពាល់របស់មនុស្សម្នាក់ទៅម្នាក់ទៀត ឧទាហរណ៍៖ការកាន់ប៉ះជាប់មេរោគរបស់អ្នកជំងឺ
- វត្ថុដែលប្រឡាក់កម្ទួតឬលាមកអ្នកជំងឺ
- ចំណីអាហារឬភេសជ្ជៈដែលមានជាតិកម្ទួតឬលាមករបស់អ្នកជំងឺ

វីរុសនេះក៏អាចឆ្លងតាមរយៈការក្អកនិងកណ្តាស់ផងដែរ។

## តើអ្នកណាខ្លះដែលអាចមានគ្រោះថ្នាក់កើតជំងឺនេះ?

- កុមារតូចៗដែលមិនស៊ាំនឹង rotavirus (ពីការធ្លាប់មានជំងឺនេះ ឬចាក់ថ្នាំបង្ការរោគ) មានគ្រោះថ្នាក់ខ្លាំងក្នុងការកើតជំងឺនេះ  ប៉ុន្តែជួនកាលមនុស្សចាស់ក៏អាចកើតជំងឺនេះផងដែរ។
- កុមារភាគច្រើនបានស៊ាំនឹង rotavirus នៅពេលមានអាយុត្រឹមបីឆ្នាំ។
- ភាពស៊ាំនឹងជំងឺ rotavirus គឺមិនពេញលេញទេ។ ជាទូទៅ ការកើតមានជំងឺនៅពេលក្រោយមកទៀតមានភាពធូរស្រាលជាងការកើតមានលើកដំបូង។
- rotavirus មានភាពទូទៅនៅក្នុងសហគមន៍ជាច់ស្រយាលខ្លះ។

## តើវិធីបង្ការជំងឺនេះធ្វើឡើងដោយរបៀបណា?

ថ្នាំបង្ការរោគដោយឥតគិតថ្លៃគួរចាក់ឲ្យកុមារមានអាយុតិចជាង 6 ខែ។ នៅក្នុងរដ្ឋ NSW កុមារចាក់ថ្នាំបង្ការរោគនេះចំនួនពីរកំរិតនៅពេលមានអាយុពីរខែនិងបួនខែ ដោយមានការបំពេញសព្វគ្រប់នូវកំរិតថ្នាំនេះនៅត្រឹមពេលមានអាយុ 24 អាទិត្យ។

Rotavirus អាចបង្ការបានតាមរយៈការលាងសំអាតដៃឲ្យបានម៉ត់ចត់រយៈពេល 10 វិនាទី ដោយប្រើសាប៊ូនិងទឹក ព្រមទាំងសម្ងួតដៃជាមួយនឹងកន្សែងពោះគោស្អាតល្អ៖

- ក្រោយពេលទៅបង្គន់
- មុនពេលរៀបចំឬទុកដាក់ចំណីអាហារ
- មុនពេលបរិភោគចំណីអាហារ
- ក្រោយពីថែទាំអ្នកណាម្នាក់ដែលមាន rotavirus (ជាពិសេសនៅក្រោយពេលផ្លាស់ក្រណាត់កន្ទបឬស្រោមខ្នើយនិងកំរាលពូកដែលប្រឡាក់)

- កុំផ្លាស់ក្រណាត់កន្ទបនៅលើផ្ទៃសំរាប់រៀបចំឬបរិភោគចំណីអាហារឲ្យសោះ
- ត្រូវសំអាតផ្ទៃនិងវត្ថុទាំងឡាយ (មានរួមទាំងប្រដាប់ក្មេងលេង)និងសំលៀកបំពាក់ដែលបានប៉ះនឹងកម្អួតឬលាមក ឲ្យបានម៉ត់ចត់ជាមួយនឹងទឹកក្តៅនិងសាប៊ូ។ ទុកឲ្យវត្ថុទាំងឡាយស្ងួតសិន ក្រោយពីបានសំអាតហើយ
- កុមារដែលរាករូស មិនគួរវិលទៅកាន់មណ្ឌលថែទាំកុមារទេ រហូតទាល់តែនៅរោគសញ្ញាទាំងឡាយបានបាត់ទៅវិញអស់ពេល 24 ម៉ោងហើយ
- អ្នកណាមួយដែលរាករូស មិនគួរហែល  ឆ្លងកាត់ឬលេងក្នុងអាងទឹក រយៈពេលយ៉ាងតិច 2 អាទិត្យ ក្រោយពីជាសះស្បើយទាំងស្រុងហើយ

## តើការវិនិច្ឆ័យរោគធ្វើទៅតាមរបៀបណា?

ជាធម្មតាមានការសង្ស័យអំពីការកើតមានជំងឺនេះដោយផ្អែកលើរោគសញ្ញាទាំងឡាយ ហើយការបញ្ជាក់អំពីរោគវិនិច្ឆ័យអាចធ្វើទៅបានតាមរយៈការធ្វើតេស្តលាមករបស់កុមារនៅក្នុងមន្ទីរពិសោធន៍។

## តើវិធីព្យាបាលជំងឺនេះធ្វើឡើងដោយរបៀបណា?

ការព្យាបាលគឺការបំពេញជាតិទឹកតាមមាត់ឡើងវិញ (ពោលគឺការទទួលទានជាតិទឹកថ្លាឲ្យបានច្រើន)ដើម្បីបង្ការកង្វះជាតិទឹក។ ចៀសវាងការទទួលទានទឹកផ្លែឈើសុទ្ធនិងភេសជ្ជៈទឹកក្រូចសុទ្ធ ដោយសារតែការទទួលទានដូចនេះអាចបង្កើនកង្វះជាតិទឹកនិងរាករូស។ ឱសថស្ថានមានលក់ភេសជ្ជៈសំរាប់បំពេញមកវិញនូវជាតិទឹកដែលបានបាត់បង់។

មិនគួរឲ្យថ្នាំពេទ្យដើម្បីបង្ការការក្អួតនិងរាករូសឡើយ ជាពិសេសទៅឲ្យកុមារ លើកលែងតែមានវេជ្ជបញ្ជាពីវេជ្ជបណ្ឌិត។

កុមារខ្លះអាចត្រូវទៅចាក់បញ្ចូលសេរ៉ូមនៅមន្ទីរពេទ្យ។

## តើផ្នែកសុខភាពសាធារណៈមានវិធានការឆ្លើយតបអ្វីខ្លះ?

ការកើតមានជំងឺរលាកក្រពះនិងពោះវៀនបង្កដោយវីរុសមានកំណើននៅរដូវរងា ហើយមានភាពទូទៅតាមមណ្ឌលថែទាំកុមារ។ វេជ្ជបណ្ឌិតនិងមន្ទីរពេទ្យទាំងឡាយត្រូវរាយការណ៍ប្រាប់ផ្នែកសុខភាពសាធារណៈ (Public Health Unit) ក្នុងតំបន់ខ្លួន នៅពេលដែលមានករណីទំនាក់ទំនងនឹងគ្នាចំនួនយ៉ាងតិចពីរករណី ក្នុងការកើតមានជំងឺរលាកក្រពះនិងពោះវៀន។

ផ្នែកសុខភាពសាធារណៈអាច៖

- ផ្តល់ឱវាទអំពីរបៀបរកមូលហេតុនៃការកើតមានជំងឺ
- ផ្តល់ឱវាទអំពីរបៀបគ្រប់គ្រងការកើតមានជំងឺ
- ជួយស៊ើបអង្កេតការកើតមានជំងឺដើម្បីកំណត់ប្រភពនិងវិធីចម្លង
- ផ្តល់ឱវាទអំពីការហាមឃាត់កុំឲ្យអ្នកជំងឺ ធ្វើដំណើរទៅមណ្ឌលថែទាំកុមារ

## ព័ត៌មានពាក់ព័ន្ធ

- ការគ្រប់គ្រងការកើតមានជំងឺ
  http://www0.health.nsw.gov.au/factsheets/infectious/rotavirus.html
- ប័ណ្ណព័ត៌មានអំពីជំងឺរលាកក្រពះនិងពោះវៀនក្នុងចំណោមកុមារ – Children's Hospital Westmead
  http://www.chw.edu.au/
- ប័ណ្ណព័ត៌មានអំពីជំងឺរលាកក្រពះនិងពោះវៀនក្នុងចំណោមកុមារ – Sydney Children's Hospital
  http://www.sch.edu.au/
- គោលការណ៍គ្រប់គ្រងជំងឺរបស់ NSW Health PD2007_036
  http://www.health.nsw.gov.au/policies/pd/2007/pdf/PD2007_036.pdf

**ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW**



**1300 066 055**

**www.health.nsw.gov.au**